សួស្តី នៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីការជិះទូក
អញ្ចឹងជាទូទៅមធ្យោបាយនៅក្នុងការធ្វើដំណើរគឺមានបី គឺមាន
យើងឃើញការធ្វើដំណើរតាមផ្លូវគោក ដែលយើងមានថ្នល់ មានផ្លូវថ្នល់ មានផ្លូវលំ
មានផ្លូវជាតិជាដើម ហើយមួយទៀតផ្លូវគោកដែរ ដែលយើងហៅថាផ្លូវដែក
អញ្ចឹងការធ្វើដំណើរតាមផ្លូវដែកគឺយើងជិះរថភ្លើង អញ្ចឹងរថភ្លើងរត់តាមផ្លូវដែក ហើយឡាន
ឬក៏រថយន្ត ម៉ូតូ គឺយើងរត់លើផ្លូវថ្នល់ ឬផ្លូវជាតិ ដែលយើងហៅថាផ្លូវគោក
ហើយមធ្យោបាយធ្វើដំណើរមួយប្រភេទទៀត គឺយើងធ្វើដំណើរតាមផ្លូវអាកាស
អញ្ចឹងដើម្បីធ្វើដំណើរតាមផ្លូវអាកាស គឺយើងជិះយន្តហោះ
ចំណែកឯមធ្យោបាយធ្វើដំណើរមួយវិញទៀតនោះ ដែលយើងតែងតែប្រើប្រាស់ដែរ
គឺជាមធ្យោបាយធ្វើដំណើរតាមផ្លូវទឹក អញ្ចឹងដើម្បីធ្វើដំណើរតាមផ្លូវទឹកបាន
គឺយើងត្រូវប្រើប្រាស់ទូក ដែលទូកមានដូចជាទូកអុំ ទូកចែវ ឬក៏ទូកម៉ាស៊ីនជាដើម អញ្ចឹងទូកខ្លះធំ
ទូកខ្លះតូច ទៅតាមប្រភេទនៃទូកនីមួយៗ ហើយពេលខ្លះយើងចង់ជិះទូកលេងកម្សាន្តតាមទឹក
ក៏យើងអាចជិះទូកបានផងដែរ ដោយទូកក៏មានដំណើរកម្សាន្តដែរ ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ
គឺជាការជិះទូកកម្សាន្តតាមផ្លូវទឹក នៅលើទឹក អញ្ចឹងយើងអាចជិះទូកកម្សាន្ត
នៅមើលនៅលើទេសភាព ជុំវិញមាត់ទឹក ហើយក៏ដូចជាទេសភាព
ដែលនៅលើច្រាំងក្បែរទឹកទន្លេផងដែរ

ដែលយើងឃើញនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ បុរសម្នាក់ គាត់កំពុងតែឈរនៅមាត់ទឹក
ដែលបុរសនោះ គាត់មានវ័យប្រហែលជា ២៥ ឆ្នាំ គាត់មានសក់ខ្លីពណ៌ខ្មៅ
ហើយគាត់ពាក់អាវពណ៌រៀងស្វាយដៃខ្លី អញ្ចឹងបុរសម្នាក់នោះ យើងឃើញទឹកមុខគាត់ញញឹម
ហើយគាត់កំពុងតែឈរនៅមាត់ទឹក ដែលយើងឃើញទឹកមានទឹករលកតិចៗផងដែរ
បានន័យថាទឹកនោះដូចជាទឹកទន្លេ អញ្ចឹងជាធម្មតានៅក្នុងទឹកទន្លេក៏មានរលកដែរ
ក៏ប៉ុន្តែវាអត់សូវរលកខ្លាំងដូចនៅក្នុងទឹកសមុទ្រនោះទេ ព្រោះទន្លេជាទឹកតូច
អញ្ចឹងវាអត់សូវមានរលកទេ អញ្ចឹងបុរសម្នាក់នោះ គាត់ឈរនៅមាត់ទន្លេ
ហើយគាត់កំពុងតែកាន់ផែនទីដើម្បីមើល អញ្ចឹងបុរសម្នាក់ហ្នឹង គាត់ឈរមាត់ទន្លេ ដើម្បីរង់ចាំជិះទូក
ដូច្នេះហើយគាត់ក៏កាន់ផែនទីមួយ ដើម្បីមើលថាតើទូកកម្សាន្ត គេចេញពីណាទៅណា
ហើយកាត់តាមកន្លែងណាខ្លះ អញ្ចឹងគាត់អាចសម្រេចចិត្តថាជិះទូកមួយណាបាន
ឬក៏ជិះទូកមួយណា ដែលទៅណាដែលគាត់ចង់ទៅ ឬក៏គាត់ចង់ទៅកន្លែងណា
គាត់អាចមើលផែនទីនោះបាន ហើយយើងឃើញនៅលើមាត់ច្រាំងម្ខាងទៀត អញ្ចឹងយើងឃើញ
គេហៅថាត្រើយម្ខាង ដែលជាទូទៅទន្លេគឺមានត្រើយចំនួនពីរ ត្រើយម្ខាង និងត្រើយម្ខាងទៀត
ដែលបុរសម្នាក់នេះ គាត់ឈរនៅត្រើយម្ខាង រីឯត្រើយម្ខាងទៀតដែលនៅទល់មុខគាត់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើងឃើញមានអគារតូចធំជាច្រើន មានខ្ពស់ មានទាប អញ្ចឹងបានន័យថាទន្លេនេះ
គឺជាទន្លេដែលនៅជាយក្រុង ដូច្នេះហើយយើងអាចឃើញស្រមោលទីក្រុងនៅខាងមុខគាត់បាន
ដែលមានអគារជាច្រើន នៅតាមមាត់ទន្លេនោះផងដែរ អញ្ចឹងបុរសម្នាក់នេះ គាត់ឈរមើលផែនទី
ហើយគាត់ចង់ជិះទូក អញ្ចឹងគាត់មើលផែនទីថាតើ គោលដៅរបស់គាត់ ត្រូវជិះទៅតាមកន្លែងណាខ្លះ
អញ្ចឹងទូកដែលគាត់ត្រូវជិះ តើគាត់ត្រូវជិះមួយណា ដូច្នេះហើយដើម្បីឲ្យច្បាស់
គឺគាត់ត្រូវតែមើលផែនទី។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ យើងឃើញថា យើងឃើញមានមនុស្សប្រុសស្រីជាច្រើន
កំពុងតែឈរនៅកំពង់ផែ អញ្ចឹងកន្លែងចំណតទូក យើងហៅថាកំពង់ផែ
ដែលយើងឃើញនៅក្នុងនោះ មានមនុស្សប្រុសស្រីក្មេងចាស់ជាច្រើន
គាត់កំពុងតែឈរនៅក្នុងរោងមួយ ដែលកំពង់ផែ យើងតែងតែឃើញមានគេដាក់ដំបូល
អញ្ចឹងដើម្បីឲ្យភ្ញៀវ ឬក៏អ្នកទេសចរណ៍ ឬក៏អ្នកដំណើរ គាត់ឈរជ្រកម្លប់
នៅក្នុងពេលកំពុងតែរង់ចាំទូក អញ្ចឹងប្រសិនបើយើងអត់ដាក់ដំបូលទេ គឺអាចធ្វើឲ្យអ្នកដំណើរក្ដៅ
ព្រោះថាទូកពេលខ្លះគឺយូរ គឺយើងរង់ចាំយូរ មុននឹងទូកនោះមកដល់ ដូច្នេះប្រសិនអត់មានដំបូល
នៅពេលដែលមេឃក្ដៅ អ្នកដំណើរទាំងអស់នឹងក្ដៅ ឬក៏នៅមេឃភ្លៀង
អ្នកដំណើរទាំងអស់នឹងទទឹកភ្លៀង អញ្ចឹងយើងត្រូវធ្វើដំបូល ដើម្បីការពារអ្នកដំណើរកុំឲ្យគាត់ពិបាក
អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមានមនុស្សជាច្រើនកំពុងតែឈរចាំទូក ដោយមាននារីម្នាក់
គាត់ឈរកាន់កាបូប ហើយបុរសម្នាក់ទៀត គាត់កំពុងតែឈរជ្រែងហោប៉ៅ ឬក៏ឈរច្រត់ចង្កេះ
ដែលយើងឃើញមាននារីពីរនាក់នៅក្បែរនោះ គាត់កំពុងតែឈរនិយាយគ្នា ហើយមានបុរសម្នាក់
គាត់កំពុងតែកាន់ផែនទីដើម្បីមើល ថាតើគាត់ត្រូវទៅណាខ្លះ គាត់ទៅដល់ណាខ្លះ
ទូករបស់គាត់ត្រូវជិះតើទៅដល់ណាខ្លះ អញ្ចឹងជាទូទៅកំពង់ផែគឺយើងតែងតែឃើញមានកង់ឡាន
ដែលនៅជាប់នឹងកន្លែងចតទូក ដើម្បីនៅពេលដែលទូកមកដល់ គឺទូកចូលជិតទៅនឹងផែ
ដូច្នេះប្រសិនបើយើងអត់ដាក់កង់ឡានទេ ឬក៏អត់ដាក់ជ័រ ឬក៏អត់ដាក់កៅស៊ូនៅទប់ទេ
ទូកអាចកកិតនឹងកំពង់ផែដែលធ្វើឲ្យទូកខូច ព្រោះកំពង់ផែរឹង ហើយទូកគឺយើងធ្វើឡើងអំពីដែក
ដូច្នេះពេលខ្លះ នៅពេលដែលដែកប៉ះនឹងរបស់រឹង វាអាចកំប៉ិត ឬក៏អាចខូច ឬក៏អាចធ្លាយបាន
នាំឲ្យមានគ្រោះថ្នាក់ ដូច្នេះដើម្បីកាត់បន្ថយការប៉ះទង្គិចគ្នារវាងទូកនិងកំពង់ផែ
គឺយើងឃើញថាគេប្រើប្រាស់កង់ឡាន ឬក៏ជ័រកៅស៊ូ ដើម្បីដាក់ទប់ កុំឲ្យទូកប៉ះផ្ទាល់ទៅនឹងកំពង់ផែ
ជាក់ស្ដែងនៅក្នុងរូបភាពនេះ យើងឃើញមានកង់ឡានចំនួនបួន ដែលកង់ឡាននោះគឺពណ៌ខ្មៅ
ហើយយើងឃើញគេចងខ្សែកង់ឡានជាប់ទៅនឹងផែរបស់ទូក
ដើម្បីកាត់បន្ថយភាពកកិតរវាងកំពង់ផែនិងទូក នៅពេលដែលវាប៉ះគ្នា។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា
បន្ទាប់ពីពួកគេឈរបានបន្តិចក្រោយមកទូកក៏មកដល់ អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញ
មានមនុស្សម្នាជាច្រើនកំពុងតែជិះទូក ដែលទូកនោះគឺជាទូកកម្សាន្ត ដែលយើងឃើញមានដំបូល
អញ្ចឹងជាទូទៅទូកតែងតែមានដំបូល ព្រោះថានៅពេលដែលយើងជិះទូក គឺយើងធ្វើដំណើរហាលថ្ងៃ
អញ្ចឹងប្រសិនបើយើងអត់ដាក់ដំបូល គឺអ្នកដំណើរទាំងអស់ ដែលនៅលើទូក គឺក្ដៅ
អញ្ចឹងពួកគេពិបាកធ្វើដំណើរខ្លាំងណាស់ ដូច្នេះដើម្បីឲ្យងាយស្រួលក្នុងការធ្វើដំណើរ
និងដើម្បីការពារកុំឲ្យអ្នកដំណើរក្ដៅ ក៏ដូចជាទទឹកទឹកភ្លៀង ទូកក៏យើងត្រូវការដាក់ដំបូលដែរ
ក៏ប៉ុន្តែទូកអត់មានជញ្ជាំងទេ អញ្ចឹងភាគច្រើនទូកកម្សាន្តគឺអត់មានជញ្ជាំងទេ
ព្រោះដើម្បីឲ្យអ្នកដំណើរទាំងអស់អាចឃើញទេសភាពនូវសងខាងបាន
ក៏ប៉ុន្តែប្រសិនបើយើងជាទូកធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ គេអាចប្រើប្រាស់ជញ្ជាំង
ដើម្បីការពារកុំឲ្យមានការ មានអ្នកដំណើរទាំងអស់មានគ្រោះថ្នាក់
ប៉ុន្តែប្រសិនបើយើងគ្រាន់តែជិះទូក ដើម្បីធ្វើដំណើរកម្សាន្តមើលទេសភាព គឺគេអត់ដាក់ជញ្ជាំងទេ
ព្រោះប្រសិនបើដាក់ជញ្ជាំងគឺវាបាំង យើងអត់អាចមើលទេសភាពបានទេ អញ្ចឹងនៅក្នុងរូបភាពនេះ
គឺទូកមកដល់កំពង់ផែ ហើយទូកក៏បានចូលជិតទៅនឹងកំពង់ផែ
ហើយទូកនោះក៏បានប៉ះទៅនឹងកង់ឡាន ដើម្បីដាក់ទប់ កុំឲ្យទូកប៉ះនូវកំពង់ផែ
អញ្ចឹងនៅពេលដែលទូកមកដល់ គឺអ្នកបើកបរទូក គាត់តែងតែចតទូកឲ្យកៀកទៅនឹងកំពង់ផែ
ឬក៏ទៅឲ្យប៉ះនឹងកង់ឡានដែលចងនឹងកំពង់ផែ ដើម្បីចតដាក់អ្នកដំណើរ
ឬក៏ឲ្យអ្នកដំណើរគាត់ចេញពីទូក ឬក៏ឲ្យអ្នកដំណើរគាត់ចុះពីលើទូក ឬក៏ចូលទៅក្នុងទូកវិញ
អញ្ចឹងយើងឃើញកំពង់ផែ គឺមានបង្កាន់ដៃដែរនៅខាងៗ ព្រោះថាដើម្បីដាក់ទប់
កុំឲ្យអ្នកដំណើរគាត់ធ្លាក់ក្នុងទឹក ព្រោះប្រសិនបើអត់ដាក់បង្កាន់ដៃទេ
ពេលខ្លះនៅពេលដែលអ្នកដំណើរមិនប្រយ័ត្ន គាត់អាចធ្លាក់ចូលក្នុងទឹក
ហើយអាចនឹងមានគ្រោះថ្នាក់បាន អញ្ចឹងគេត្រូវដាក់បង្កាន់ដៃនៅសងខាង ដើម្បីទប់ពេល
ពេលដែលអ្នកដំណើរគាត់ទៅជិតកំពង់ផែ ឬក៏ទៅជិតនឹងទឹក គឺវានឹងទើសបង្កាន់ដៃ
ដូច្នេះវាអត់អាចធ្លាក់ទេ អ្នកដំណើរអត់អាចធ្លាក់ទេ។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា បន្ទាប់ពីទូកមកដល់ហើយ
បន្ទាប់ពីទូកមកដល់ យើងឃើញអ្នកដំណើរទាំងអស់ ដែលនៅខាងលើកំពង់ផែ
គឺគាត់អត់ទាន់ចុះចូលទូកទេ ព្រោះថាមនុស្សនៅក្នុងទូកគឺច្រើន ដូច្នេះនៅពេលដែលទូកមកដល់
គឺគេអ្នកនៅខាងលើរង់ចាំឲ្យអ្នកនៅក្នុងទូក គាត់ចេញពីទូកឲ្យអស់សិន
ព្រោះប្រសិនបើគាត់បញ្ជៀតគ្នាចូល ឬក៏ដណ្ដើមគ្នាចូល គឺអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន
ដោយសារការប៉ះទង្គិចគ្នាអាចធ្វើឲ្យយើងដួល ឬក៏អាចធ្វើឲ្យយើងធ្លាក់ទៅក្នុងទឹក

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នាំឲ្យមានគ្រោះថ្នាក់បាន ដូច្នេះគឺយើងអត់ត្រូវបញ្រៀតគ្នា ឬក៏អត់ត្រូវបង្ខំពេកទេ
គឺយើងត្រូវចុះតាមសម្រួលម្តងម្នាក់ៗ ដោយជាក់ស្តែងនៅក្នុងរូបភាពទី ៤ នេះ
យើងឃើញមានមនុស្សប្រុសស្រីជាច្រើន គាត់កំពុងតែចេញពីទូក ដោយយើងឃើញនៅខាងមុខគេ
គឺមានបុរសម្នាក់និងនារីម្នាក់ ដែលពាក់អាវពណ៌ទឹកក្រូច ដែលបុរសម្នាក់នោះ
គាត់កំពុងតែដើរចេញពីទូក ហើយនារីម្នាក់នោះ គាត់កាន់កាបូបរបស់គាត់
ដោយដៃខាងស្តាំរបស់គាត់ ដោយដៃខាងឆ្វេងរបស់គាត់ គាត់កាន់យួរកាបូប
គឺដៃកាបូបរបស់គាត់ដាក់ចូលទៅក្នុងដើមដៃខាងឆ្វេង ហើយគាត់យួរទៅដើម្បីចេញពីទូក
ចំណែកឯបន្ទាប់មកគឺឃើញ យើងឃើញមានបុរសពាក់អាវពណ៌បៃតង នារីពាក់អាវពណ៌ស នារី
បុរសដែលពាក់អាវពណ៌ស្វាយដៃវែង និងមនុស្សពីរនាក់ផ្សេងទៀតកំពុងតែចេញពីទូក
ហើយដើរសំដៅទៅរកគោលដៅរបស់គេដែលចង់ទៅ អញ្ចឹងពួកគេគឺជាអ្នកដំណើរដែលនៅលើទូក
ឬក៏មកពីគោលដៅផ្សេង ដូច្នេះពួកគេមកដល់គោលដៅមួយនេះ គឺពួកគេត្រូវចុះ
ហើយទៅកន្លែងដែលពួកគេចង់ទៅ ចំណែកឯអ្នកដំណើរផ្សេងទៀត ដែលមិនទាន់ឡើងលើទូក
ពួកគាត់អត់ទាន់ឡើងទេ ជាក់ស្តែងគឺបុរសដែលពាក់អាវពណ៌ស្វាយដៃខ្លី ដែលកាន់ផែនទី
និងនារីម្នាក់ដែលពាក់អាវពណ៌បៃតង សំពត់ពណ៌លឿង ដែលយួរកាបូប
គឺគាត់អត់ទាន់ឡើងលើទូកទេ គឺគាត់រង់ចាំមើលតើអ្នកដំណើរចេញពីលើទូកអស់ឬនៅ
អញ្ចឹងប្រសិនបើអត់ទាន់អស់ទេ គាត់ក៏អត់ទាន់ឡើងដែរ ដោយសារតែខ្លាចប៉ះទង្គិចគ្នា
ធ្វើឲ្យមានគ្រោះថ្នាក់ អញ្ចឹងគាត់ចាំ រង់ចាំទាល់តែអ្នកដំណើរដែលនៅលើទូក គាត់ចេញអស់
បានន័យថាអ្នកណាមកដល់គោលដៅគាត់ចេញអស់ហើយ ហើយលែងមានអ្នកចេញពីទូកហើយ
ទើបពួកគាត់ដើរចូល។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ បន្ទាប់ពីអ្នកដំណើរគាត់ចេញអស់ពីទូកហើយ
យើងឃើញបុរសដែលពាក់អាវស្វាយ គាត់ក៏បានដើរចូលទៅក្នុងទូកម្តង
អញ្ចឹងជាទូទៅគឺទូកនិងកំពង់ផែ គឺអត់នៅកៀកគ្នាទេ គឺមានចន្លោះធំ
ព្រោះយើងឃើញថាគម្លាតនៃកង់ឡាន ទំហំកង់ឡានគឺក្រាស់
អញ្ចឹងនៅពេលដែលទូកប៉ះនឹងកង់ឡាន គឺធ្វើឲ្យវាអត់ដល់ផែទេ អត់ដល់កំពង់ផែទេ
ដូច្នេះធ្វើឲ្យមានចន្លោះ អញ្ចឹងនៅពេលដែលយើងឡើងលើទូក យើងត្រូវឈានជំហានឲ្យធំ
ឬក៏បោះជំហានឲ្យវែង ជាក់ស្តែងបុរសម្នាក់នេះ គាត់បោះជំហានយ៉ាងវែង ដើម្បីឡើងលើទូក
ដោយជើងឆ្វេងរបស់គាត់នៅលើកំពង់ផែ រីឯជើងស្តាំគាត់ឈានយ៉ាងវែងឡើងទៅលើទូក
ដោយសារតែទូកនិងកំពង់ផែគឺមានចន្លោះរវាងគ្នានិងគ្នា គឺអត់ជិតគ្នាទេ
អញ្ចឹងប្រសិនបើយើងឈានជំហានតិចពេក យើងឈានជំហានយើងជំហានខ្លីពេក
គឺអាចធ្វើឲ្យយើងមិនដល់ទូក ឈានអត់ដល់ទូក ដូច្នេះវាអាចធ្វើឲ្យយើងធ្លាក់នៅក្នុងទឹក

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ធ្វើឲ្យមានគ្រោះថ្នាក់បាន ឬក៏ធ្វើឲ្យយើងជួលប៉ះទង្គិចទៅនឹងទូក
ដែលអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បានដូចគ្នា អញ្ចឹងដើម្បីឡើងលើទូក
យើងត្រូវបោះជំហានឲ្យវែងៗ ឲ្យផុតចន្លោះ ដើម្បីកុំឲ្យធ្លាក់ទឹក ម្យ៉ាងវិញទៀតប្រសិនបើក្មេង
ក្មេងគាត់អត់អាចឈានដល់ទេ គឺគាត់ឈានអត់ដល់ទេ អញ្ចឹងប្រសិនបើមានក្មេងចង់ជិះទូក
យើងត្រូវលើកពោរក្មេងឡើង ឬក៏ជួយលើកក្មេង ដើម្បីដាក់ចូលទៅលើទូក
ដោយអត់ឲ្យគាត់ឈានខ្លួនឯងទេ ព្រោះថាប្រសិនបើគាត់ឈានឡើងលើទូកខ្លួនឯង
គាត់អាចនឹងមានគ្រោះថ្នាក់ ដោយសារតែគាត់ឈានអត់ដល់ ជាក់ស្ដែងបុរសម្នាក់នេះ
គាត់បោះជំហានយ៉ាងវែង ដោយដៃរបស់គាត់ម្ខាងកាន់ផែនទី
ហើយដៃម្ខាងរបស់ទៀតគាត់បោះថយក្រោយ គឺដើម្បីឈានជំហានឲ្យបានវែង
ហើយយើងឃើញនារីដែលឈរខាងក្រោយនោះ គាត់កំពុងតែដើរឡើងលើទូកដែរ
ដោយដៃម្ខាងគាត់យួរកាបូប ដៃម្ខាងគាត់តោងទូកនៅខាងលើ បានន័យថាគាត់តោងដំបូលទូក
ហើយគាត់ក៏ឈានជើងឡើងលើទូកផងដែរ ដោយអ្នកទាំងពីរត្រូវឈានជំហានឲ្យវែងៗ
ដើម្បីឡើងលើទូក កុំឲ្យមានគ្រោះថ្នាក់ ឬកុំឲ្យរអិលដួល ឬក៏ធ្លាក់ចូលទៅក្នុងទឹក។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា
បន្ទាប់ពីពួកគាត់ឡើងមកដល់លើទូកអស់ហើយ អញ្ចឹងនៅពេលដែលគាត់ឡើងលើទូក
គឺជាធម្មតាតែងតែមានអ្នកលក់សំបុត្រទូកមកក្បែរគាត់ ដើម្បីលក់សំបុត្រទៅឲ្យគាត់
អញ្ចឹងជាទូទៅទូកគឺអត់សូវដូចឡានក្រុងនិងអត់ដូចយន្តហោះទេ
គឺឡានក្រុងនៅពេលដែលយើងឡើងជិះ យើងត្រូវទិញសំបុត្រជាមុនសិន ដើម្បីជិះឡានក្រុង
ប៉ុន្តែទូកលុះត្រាតែយើងទៅដល់ឡើងលើទូកហើយ ទើបគេលក់សំបុត្រឲ្យយើងតាមក្រោយ
អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពនេះ យើងឃើញបុរសម្នាក់ដែលពាក់អាវពណ៌ស្វាយដៃខ្លីនោះ
គាត់កំពុងតែអង្គុយនៅលើកៅអី ហើយមានបុរសម្នាក់ទៀត ដែលមានវ័យចំណាស់ អាយុប្រហែលជា
៤០ ឆ្នាំ គឺយើងឃើញសក់គាត់ទំពែកនិងមានស្កូវផងដែរ អញ្ចឹងសក់សៗ យើងហៅថាស្កូវ
អញ្ចឹងបុរសម្នាក់នោះ គាត់អង្គុយពីក្រោយ បុរសដែលពាក់អាវស្វាយដៃខ្លី
ហើយនៅក្បែរបុរសដែលពាក់អាវស្វាយដៃខ្លី គឺមានកៅអីមួយទៀត ដែលអត់ទាន់មានមនុស្សអង្គុយ
អញ្ចឹងកៅអីមានពីរ ប៉ុន្តែអត់ទាន់មានមនុស្សអង្គុយទេ គឺគាត់ទើបតែអង្គុយម្នាក់ឯង
ជាមួយនឹងបុរសសក់ស្កូវម្នាក់ ដែលអង្គុយពីក្រោយ ដែលកៅអីទំនេរ
គាត់ដាក់ផែនទីរបស់គាត់នៅលើនោះ អញ្ចឹងនៅពេលដែលកៅអីទំនេរ
យើងអាចដាក់សម្ភារៈនៅលើនោះបាន ក៏ប៉ុន្តែប្រសិនបើមានអ្នកដំណើរផ្សេងទៀតមក
យើងត្រូវដកសម្ភារៈរបស់យើងចេញ ដើម្បីឲ្យអ្នកដំណើរផ្សេងទៀតអង្គុយ ហើយបុរសម្នាក់នោះ
គាត់ក៏បានសម្លឹងទៅលើ ទៅមើលបុរសម្នាក់ទៀត ដែលពាក់ឯកសណ្ឋានជាអ្នកលក់សំបុត្រ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅលើទូកគឺយើងតែងតែមានឯកសណ្ឋានមួយសម្រាប់បុគ្គលិក ដើម្បីកុំឲ្យច្រឡំជាមួយនឹងអ្នកដំណើរ ជាក់ស្តែងនៅក្នុងរូបភាពនេះ គឺមានបុរសម្នាក់ ពាក់អាវសដៃខ្លី ស្លៀកខោពណ៌សដែរ គាត់កំពុងតែដើរលក់សំបុត្រឲ្យអតិថិជន អញ្ចឹងប្រសិនបើអតិថិជនណាអត់ទិញសំបុត្រទេ គឺគាត់អត់ឲ្យជិះទូកនោះទេ គឺគាត់ឲ្យចេញពីទូកវិញ ដូច្នេះហើយអ្នកដែលជិះទូកទាំងអស់ត្រូវតែទិញសំបុត្រដើម្បីជិះទូក។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ គឺបន្ទាប់ពីបុរសអ្នកលក់សំបុត្រមកដល់ហើយ គាត់ក៏បានបើកប្រអប់សំបុត្រមួយ ប្រអប់សំបុត្រប្រភេទនេះគឺជាប្រអប់សំបុត្រដែលមានវិល មានកង់វិល ដែលអតិថិជនទាំងអស់ត្រូវចាប់ទាញសំបុត្រចេញពីប្រអប់នោះ ហើយផ្តាច់យកត្រឹមតែសំបុត្រមួយតែប៉ុណ្ណោះ បន្ទាប់មកត្រូវដាក់លុយចូលទៅក្នុងបំពង់នោះ អញ្ចឹងបំពង់នេះគឺជាបំពង់លក់សំបុត្រផង មានសំបុត្រនៅក្នុងនោះផង និងមានកន្លែងដាក់ប្រាក់ផង ដែលនៅក្នុងរូបភាពនេះ គឺជារូបភាពដែលយើងចាយកាក់ អញ្ចឹងបានន័យថានៅពេលដែលគាត់ទាញសំបុត្រចេញ គឺគាត់ត្រូវបោះកាក់តម្លៃនៃសំបុត្រនោះ ចូលទៅក្នុងបំពង់នោះវិញ ដោយអ្នកលក់សំបុត្រ គឺគាត់បើកបំពង់នោះ ដើម្បីឲ្យអ្នកដំណើរចាប់ទាញសំបុត្រ អញ្ចឹងជាទូទៅនៅក្នុងប្រទេសកម្ពុជា គឺយើងអត់សូវមានការលក់សំបុត្របែបនេះទេ គឺនៅប្រទេសកម្ពុជា ដើម្បីជិះទូក គឺយើងត្រូវបង់លុយដើម្បីទិញសំបុត្រនៅលើកំពង់ផែ ដោយហើយជាទូទៅ គឺកំពង់ផែនៅក្នុងប្រទេសកម្ពុជា គឺអត់មានទូកដើម្បីជិះធ្វើដំណើរទៅកន្លែងមួយទៅកន្លែងមួយទេ គឺមានតែទូកដើម្បីជិះដំណើរកម្សាន្តនៅក្នុងទន្លេ ហើយត្រលប់មកវិញ ហើយយើងទិញសំបុត្រនៅលើកំពង់ផែ ប៉ុន្តែនៅក្នុងរូបភាពនេះ គឺជារូបភាពដែលលក់សំបុត្រតាមរយៈបំពង់ តាមរយៈអ្នកលក់សំបុត្រនៅលើទូក អញ្ចឹងបានន័យថានៅក្នុងប្រទេសកម្ពុជាគឺអត់មានទេ ហើយនៅក្នុងរូបភាពនេះគឺគេចាយកាក់ ដែលជាភាគច្រើន ចាយកាក់គឺ កម្ពុជាអត់មានចាយកាក់ទេ គឺយើងចាយលុយរៀល បានន័យថាលុយក្រដាសប្រាក់ ប៉ុន្តែប្រទេសដែលចាយកាក់គឺមានដូចជាប្រទេសវៀតណាម ប្រទេសថៃជាដើម ដែលគាត់ចាយកាក់ អញ្ចឹងនៅក្នុងរូបភាពនេះ អាចជាការជិះទូកនៅក្នុងប្រទេសថៃក៏ថាបានដែរ ព្រោះមានចាយកាក់ អញ្ចឹងនៅក្នុងរូបភាពនេះ អ្នកដំណើរគាត់ត្រូវទាញសំបុត្រចេញពីបំពង់នោះ ហើយគាត់ត្រូវដាក់លុយ ឬក៏កាក់ចូលទៅក្នុងបំពង់នោះវិញ ដើម្បីឲ្យអ្នកលក់សំបុត្រយកទៅលក់សំបុត្រឲ្យអ្នកដទៃទៀត ដោយមនុស្សម្នាក់ទាញបានសំបុត្រតែមួយសន្លឹកតែប៉ុណ្ណោះ ហើយម្នាក់ទៀតត្រូវ ប្រសិនបើយើងមានគ្នាពីរនាក់ គឺយើងទាញពីរសំបុត្រ ហើយត្រូវដាក់លុយតម្លៃចំនួនពីរសំបុត្រ ចូលទៅក្នុងបំពង់នោះផងដែរ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា
បន្ទាប់ពីអ្នកដំណើរឡើងពេញទូកហើយ ទូកនោះក៏ចាប់ផ្ដើមចេញដំណើរ
អញ្ចឹងទូកនេះគឺជាទូកកម្សាន្ត ប្រហែលជាទូកកម្សាន្ត ឬក៏ជិះកម្សាន្តតាមដងទន្លេ
ដូច្នេះហើយយើងឃើញទូកនេះវែង ហើយវែង ហើយមានមនុស្សជាច្រើន កំពុងតែអង្គុយនៅលើទូក
ដែលមានក្មេងចាស់ស្រីប្រុសជាច្រើន ហើយយើងឃើញទូកគឺមានដំបូល និងមានពីរជាន់
បានន័យថាដំបូលគឺមានពីរជាន់ ដែលដំបូលទីមួយគឺទាប ហើយដំបូលខាងក្រោយគឺខ្ពស់
ដែលនៅលើដំបូលទាំងពីរគឺមានដោតទង់ជាតិ អញ្ចឹងជាទូទៅទូកនីមួយៗតែងតែមានទង់ជាតិ
ដើម្បីសម្គាល់ថាតើទូកនេះជាទូករបស់ប្រទេសមួយណា ព្រោះពេលខ្លះការដឹកជញ្ជូនអីវ៉ាន់តាមទូក
ក៏អាចធ្វើដំណើរតាមផ្លូវទឹកផងដែរ អញ្ចឹងយើងត្រូវដោតទង់ជាតិ ដើម្បីឲ្យដឹងថា
ទូកនោះមកពីប្រទេសមួយណា ហើយទូកកម្សាន្តដែលជិះតាមដងទន្លេ
ក៏យើងត្រូវដោតទង់ជាតិផងដែរដើម្បីសម្គាល់ ជាក់ស្ដែងនៅក្នុងរូបភាពនេះគឺទូកជិះកម្សាន្តមួយនេះ
គឺគាត់ដោតទង់ជាតិពីរទៅលើទូករបស់គាត់ ដើម្បីសម្គាល់ថា ទូកនេះជាទូករបស់ប្រទេសណា
ដោយសារតែធ្វើដំណើរតាមផ្លូវទឹកគឺជួបនឹងរលក ជាទូទៅគឺទឹកគឺតែងតែមានរលក មិនថាទឹកទន្លេ
ឬក៏ទឹកសមុទ្រនោះទេ គ្រាន់តែថាទឹកទន្លេគឺរលកតូចជាងទឹកសមុទ្រតែប៉ុណ្ណោះ
អញ្ចឹងនៅពេលដែលទូកធ្វើដំណើរកាត់រលកវាតែងតែឃ្លោង អញ្ចឹងពាក្យថាឃ្លោង
បានន័យថាវាផ្អៀងម្ដងទៅឆ្វេង ម្ដងទៅស្ដាំ ម្ដងឡើងលើ ម្ដងចុះក្រោម ទៅតាមចង្វាក់នៃទឹករលក
ដូច្នេះធ្វើឲ្យទូកអត់នឹងនោះទេ អញ្ចឹងអ្នកដែលជិះនៅលើទូកក៏អត់នឹងដែរ គឺឃ្លោងទៅតាមទឹករលក
ម្ដងផ្អៀងទៅឆ្វេង ម្ដងផ្អៀងទៅស្ដាំ ម្ដងបះឡើងលើ ម្ដងមុជចុះក្រោម
គឺទឹករលកធ្វើឲ្យទូកមិនមានលំនឹង បាត់បង់លំនឹង អញ្ចឹងទឹករលកធ្វើឲ្យទូកបាត់បង់លំនឹង
ដូច្នេះអ្នកជិះនៅក្នុងទូក គឺត្រូវតែប្រុងប្រយ័ត្នជានិច្ច ហើយត្រូវតោងឲ្យជាប់
ជាពិសេសក្មេងៗគឺយើងអត់ត្រូវប្រលែងឲ្យវារត់ផ្ដេសផ្ដាសទេ ប្រសិនបើក្មេងរត់នៅលើទូក
អាចនឹងមានគ្រោះថ្នាក់ ដោយសារតែទឹករលកឃ្លោងទូក ធ្វើឲ្យវាដួល ឬក៏ពេលខ្លះ
នៅពេលដែលទឹករលកខ្លាំង ធ្វើឲ្យឃ្លោងទូកខ្លាំង អញ្ចឹងក្មេងអាចធ្លាក់ពីលើទូកបាន
ដូច្នេះប្រសិនបើក្មេងធ្លាក់ពីលើទូក ប្រសិនបើក្មេងនោះអត់ចេះហែលទឹកទេ គឺវាអាចលង់ស្លាប់បាន
ដូច្នេះវាអាចមានគ្រោះថ្នាក់ដល់ជីវិត អញ្ចឹងយើងត្រូវប្រុងប្រយ័ត្នជានិច្ចនៅពេលដែលយើងជិះទូក
ហើយយើងអត់ចេះហែលទឹក ប្រសិនបើយើងអត់ចេះហែលទឹក គឺមានគ្រោះថ្នាក់ខ្លាំងណាស់
នៅពេលដែលលិចទូក។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា ជារឿងរាល់ពេល
នៅពេលដែលយើងជិះទូក គឺទូកតែងតែឃ្លោង ម្ដងផ្អៀងឆ្វេង ម្ដងផ្អៀងស្ដាំ ម្ដងបះឡើងលើ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ម្តងមុជចុះក្រោម អញ្ចឹងអ្នកជិះទូកគឺភាគច្រើនគឺគាត់ពុលរលក អញ្ចឹងអាការៈពុលរលក គឺស្រដៀងនឹងអាការៈពុលឡានដែរ ការពុលឡាន ពុលយន្តហោះ ពុលរលក គឺមានអាការៈដូចគ្នា ដែលយើងមានអាការៈវិលមុខ ឈឺក្បាល និងចង់ក្អួត ដោយសារតែយើងមិនអាចទប់ទល់ និងការឃ្លើងឃ្លោងរបស់ទូកបាន ដែលជាក់ស្តែងអ្នកខ្លះដែលគាត់មានសុខភាពខ្សោយ អ្នកខ្លះដែលគាត់មានសុខភាពទន់ខ្សោយ គឺគាត់តែងតែពុល មិនថាគាត់ជិះឡាន ជិះយន្តហោះ ឬក៏ជិះទូកនោះទេ គឺនៅពេលដែលគាត់ជិះបានបន្តិច គឺគាត់តែងតែមានអាការៈឈឺក្បាល វិលមុខ និងចង់ក្អួត ដែលជាក់ស្តែងបុរសដែលនៅក្នុងរូបភាពទី ៩ នេះ បុរសដែលពាក់អាវពណ៌ស្វាយដៃខ្លី គឺគាត់កំពុងតែពុលរលក ដោយយើងឃើញគាត់កំពុងតែយកដៃខ្ទប់ក្បាលរបស់គាត់ បានន័យថាគាត់ឈឺក្បាល ឬក៏វិលមុខយ៉ាងខ្លាំង ដែលយើងឃើញភ្នែករបស់គាត់ កំពុងតែស្រឡេវ គឺសម្លឹងទៅរកគ្នាទៅវិញទៅមក អញ្ចឹងគាត់មានអារម្មណ៍ថាវិលមុខ ដោយសារតែពុលរលក ហើយមាត់របស់គាត់គឺកំពុងតែក្រៀម ឬក៏កំពុងតែខំបិទមាត់ ព្រោះថាមាត់របស់គាត់គឺគាត់ចង់ក្អួត អញ្ចឹងអ្នកដែលពុលរលកទាំងអស់ គឺតែងតែចង់ក្អួត មានអាការៈចង់ក្អួត និងវិលមុខ និងឈឺក្បាល ដូច្នេះដូចជាមនុស្សឈឺ អញ្ចឹងដែរគឺមិនស្រួលក្នុងខ្លួននោះទេ គឺតែងតែឈឺក្បាល វិលមុខ នៅពេលដែលយើងពុលរលក ដូច្នេះបុរសម្នាក់នេះ នៅក្នុងរូបភាពទី ៩ នេះ គឺគាត់កំពុងតែពុលរលក និងមានអាការៈឈឺក្បាល វិលមុខ និងចង់ក្អួត។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា ជាទូទៅការជិះទូក គឺមិនមែនជិះតែឯងនោះទេ បានន័យថាមានទូកផ្សេងទៀត ក៏មានការបើកបរនៅលើផ្លូវទឹកនោះដែរ អញ្ចឹងការធ្វើដំណើរតាមផ្លូវទឹក មានដូចជាទូកកាណូត មានដូចជាកប៉ាល់ធំៗជាច្រើន អញ្ចឹងប្រសិនបើកប៉ាល់ពីរជិះទន្ទឹមគ្នា អាចនឹងសាចទឹកដាក់គ្នា ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១០ នេះ ប្រហែលជាមានកប៉ាល់ធំណាមួយ ឬក៏ប្រហែលជាមានកប៉ាល់លឿនណាមួយ ជិះមកក្បែរទូករបស់គាត់ ដូច្នេះហើយធ្វើឲ្យមានសាចទឹកពីក្នុងទន្លេចូលទៅក្នុងទូក អញ្ចឹងប្រសិនបើយើងជិះនៅក្នុងទូកដែលអត់មានជញ្ជាំង ហើយយើងអង្គុយខាងគេ នៅពេលដែលមានទឹករលកសាចចូល គឺអាចធ្វើឲ្យយើងសើមក្នុងខ្លួនបាន គឺអាចធ្វើឲ្យយើងសើមបាន ដូច្នេះយើងត្រូវតែប្រុងប្រយ័ត្ន នៅពេលដែលអង្គុយនៅលើទូក ព្រោះថាពេលខ្លះ នៅពេលដែលមានទូកណាលឿន ឬក៏មានទូកធំជាងទូកដែលយើងអង្គុយ ជិះនៅក្បែរយើង គឺនឹងខ្ទាតទឹករលកចូលទៅក្នុងទូក ដែលធ្វើឲ្យយើងសើមបាន សើមសម្លៀកបំពាក់ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១០ នេះ យើងឃើញថា មានទឹករលកមួយយ៉ាងធំ បានជះចូលទៅក្នុង បានសាចចូលទៅក្នុងទូក ដែលធ្វើឲ្យសើមទៅដល់បុរស ដែលពាក់អាវពណ៌ស្វាយដៃខ្លី និងបុរសចំណាស់ម្នាក់ ដែលពាក់អាវពណ៌សនោះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺគាត់សើមទាំងពីរនាក់តែម្តង ដោយសារតែរលកទឹកធំពេក ដោយសារតែមានទូកធំ ជិះមកក្បែរ ដូច្នេះហើយធ្វើឲ្យមានទឹកសាចចូលទៅក្នុងទូករបស់គាត់ដែលកំពុងអង្គុយ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ គឺទូកបានមកដល់កំពង់ផែមួយទៀតហើយ អញ្ចឹងនៅពេលដែលមកដល់កំពង់ផែ អ្នកដែលត្រូវធ្វើដំណើរមកកំពង់ផែមួយនេះ គឺត្រូវចុះពីលើទូកទាំងអស់ អញ្ចឹងជាក់ស្តែងបុរសម្នាក់នេះ គាត់ចង់ចុះនៅក្នុងកំពង់ផែមួយនេះ ដូច្នេះនៅពេលដែលទូកឈប់ គាត់ក៏បានចេញពីទូក អញ្ចឹងយើងឃើញ យើងឃើញនៅក្នុងរូបភាពនេះ គឺយើងឃើញថា នៅពេលដែលទូកចត គឺអត់មានលំនឹងទេ អញ្ចឹងទូកអាចអណ្តែតទៅកន្លែងផ្សេងទៀតបាន ដូច្នេះដើម្បីទប់ឲ្យវាលំនឹង ដើម្បីឲ្យទប់ឲ្យវានឹងមានមួយកន្លែង គឺយើងត្រូវប្រើខ្សែពួរ ដើម្បីថ្ពក់ជាប់ទៅនឹងកំពង់ផែ ដែលយើងឃើញនៅក្នុងរូបភាពនេះ កន្ទុយទូក គឺមានខ្សែមួយចងនឹងទូក ដែលខ្សែពួរធំ ជាទូទៅយើងប្រើខ្សែពួរ ដើម្បីចងនឹងទូក ហើយកន្ទុយខ្សែម្ខាងទៀត គឺថ្ពក់ជាប់ទៅនឹងបង្គោលដែកនៅកំពង់ផែ ការធ្វើដូច្នេះគឺធ្វើឲ្យទូកមិនរលក ឬក៏មិនអណ្តែតទៅកន្លែងណាផ្សេងក្រៅពីកំពង់ផែ ក៏ប៉ុន្តែទូកដែលចតនៅកំពង់ផែ ជាទូទៅតែងតែមានចន្លោះធំ បានន័យថាគម្លាតពីកំពង់ផែទៅទូកគឺធំ ដែលយើងមើលឃើញថា គម្លាតទាំងនោះគឺធំ ដូច្នេះអ្នកដំណើរទាំងអស់ ដែលត្រូវឡើងលើទូក ឬក៏ត្រូវចុះពីទូក ត្រូវបោះជំហានឲ្យបានវែងៗ ដើម្បីឈានពីទូកមកដល់កំពង់ផែ ប្រសិនបើយើងឈានជំហានខ្លីពេក គឺអាចធ្វើឲ្យយើងធ្លាក់ចូលក្នុងទឹក និងមានគ្រោះថ្នាក់បាន ឬក៏ដួល ឬក៏ទាក់ជើងដួល អាចធ្វើឲ្យយើងមានគ្រោះថ្នាក់គ្រលុកដៃគ្រលុកជើង ឬក៏បែកក្បាលជាដើម អញ្ចឹងយើងត្រូវបោះជំហានឲ្យវែងៗដើម្បីចេញពីទូក ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ គឺបុរសម្នាក់នេះ គឺគាត់បានបោះជំហានយ៉ាងវែង បោះចេញពីទូក ឡើងមកលើកំពង់ផែ។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ យើងឃើញថា មានប្រភេទទូកជាច្រើន ដែលធ្វើដំណើរតាមផ្លូវទឹក អញ្ចឹងនៅក្នុងការធ្វើដំណើរតាមផ្លូវទឹក គឺយើងមានមធ្យោបាយជាច្រើន ដូចជានៅក្នុងរូបភាពទី ១២ នេះ បុរសម្នាក់ គាត់កំពុងតែអុំទូក អញ្ចឹង[មាន]ទូកមានប្រភេទជាច្រើន ដូចជាទូកអុំ ទូកចែវជាដើម ដែលទូកអុំនេះគឺយើងប្រើ[ច្រវា] យើងឃើញបុរសម្នាក់នេះ គាត់កំពុងតែអង្គុយ ហើយដៃរបស់គាត់ទាំងពីរកំពុងតែកាន់[ច្រវា] ដើម្បីចែវទូក អញ្ចឹងគាត់ចែវចុះឡើងៗ ដោយកាយទឹក ដើម្បីឲ្យទូកទៅមុខ ដែលយើងឃើញរូបភាពនេះ គឺដៃបុរសម្នាក់នេះ គាត់កំពុងតែបោះត្រង់ទៅមុខ ហើយកាន់[ច្រវា] ដែល[ច្រវា] កន្ទុយ[ច្រវា]នៅក្នុងទឹក គល់[ច្រវា]ដែលគាត់កំពុងតែកាន់ ហើយកន្ទុយ[ច្រវា]កំពុងតែបក់ទឹក ឬក៏កាយទឹក ដើម្បីឲ្យទូកលូនទៅមុខ ដែលទូកនេះគេហៅថាទូកអុំ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ គឺជាប្រភេទទូកក្ដោង អញ្ចឹងនៅក្នុងនេះ ក្រៅពីទូកអុំ យើងនឹងមានទូកក្ដោងទៀតផងដែរ ដែលទូកក្ដោងគឺយើងអត់ប្រើម៉ាស៊ីនទេ គឺយើងអត់ប្រើម៉ាស៊ីនទេ ហើយក៏យើងអត់ប្រើច្រវ៉ាដើម្បីអុំ ឬក៏ចែវដែរ គឺយើងប្រើក្ដោង អញ្ចឹងទូកប្រភេទនេះ គឺពឹងទៅលើកម្លាំងខ្យល់ នៅពេលណាដែលមានកម្លាំងខ្យល់ នោះទូកនោះនឹងទៅមុខ ដោយសារតែក្ដោងគឺជាប្រភេទក្រណាត់កៅស៊ូមួយ ដែលទប់លំនឹងខ្យល់ អញ្ចឹងគេចងក្រណាត់ឬក៏កៅស៊ូនោះជាបន្ទះធំដោយត្រដាងទៅលើអាកាស ឬក៏ជាប់នឹងទូក ត្រដាងទៅខាងលើ ហូតទៅខាងលើ ដូច្នេះនៅពេលដែលមានខ្យល់មកបក់នឹងក្រណាត់នោះ ឬក៏បក់នឹងផ្ទាំងកៅស៊ូនោះ នឹងរុញទូកឲ្យទៅមុខតាមកម្លាំងខ្យល់ជាក់ជាពុំខាន ដូច្នេះទូកនេះគឺគេអត់ប្រើម៉ាស៊ីនទេ ម៉ាស៊ីនក៏គេអត់ប្រើ ច្រវ៉ាក៏គេអត់ប្រើដែរ គឺគេប្រើខ្យល់ គឺគេប្រើក្រណាត់ដើម្បីឲ្យខ្យល់បក់មកចំក្រណាត់ ហើយរុញទូកឲ្យទៅមុខ។

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា មានទូកមួយទៀត ដែលទូកនេះគឺជាទូកម៉ាស៊ីន អញ្ចឹងទូកម៉ាស៊ីនគឺជាទូកមួយប្រភេទ ដែលយើងប្រើប្រាស់ម៉ាស៊ីន ដើម្បីធ្វើឲ្យទូកនោះទៅមុខ ដោយយើងអត់ប្រើចំណាយកម្លាំងមនុស្សនោះទេ អញ្ចឹងវាខុសពីទូកអុំនិងទូកក្ដោង ដោយសារតែទូកក្ដោងប្រើប្រាស់កម្លាំងខ្យល់ ចំណែកឯទូកអុំគឺប្រើប្រាស់កម្លាំងមនុស្ស កាន់ច្រវ៉ាកាយទឹកដើម្បីឲ្យទូកទៅមុខ ចំណែកឯទូកមួយទៀតនេះ គឺនៅក្នុងរូបភាពទី ១៤ នេះ គឺជាប្រភេទទូកម៉ាស៊ីន ដែលយើងហៅថាកាណូត អញ្ចឹងទូកប្រភេទនេះគឺលឿន ដោយសារតែវាប្រើប្រាស់ម៉ាស៊ីននិងម៉ូទ័រនៅខាងក្រោយ អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពនេះ យើងឃើញថា ទូកនេះគឺមានលក្ខណៈបះខាងមុខ ដោយសារតែវាលឿន ដូច្នេះមនុស្សនៅអង្គុយខាងក្រោយ និងម៉ាស៊ីននៅខាងក្រោយ អញ្ចឹងវាធ្ងន់ជាងខាងមុខ ដូច្នេះធ្វើឲ្យវាបះខាងមុខ និងម្យ៉ាងទៀតដោយសារតែទូកនេះលឿងផង ដូច្នេះវាធ្វើឲ្យវាបះ ដោយសារតែកម្លាំងម៉ាស៊ីនខ្លាំង អញ្ចឹងនៅពេលដែលម៉ាស៊ីនខ្លាំង នោះទូកនោះកាន់តែលឿន ដោយយើងអត់ចាំបាច់ចំណាយកម្លាំង ដើម្បីអុំ ឬក៏ពឹងពាក់ទៅលើខ្យល់ ដើម្បីឲ្យវាទៅមុខនោះទេ យើងគ្រាន់តែប្រើប្រាស់កម្លាំងម៉ាស៊ីន ដែលម៉ាស៊ីននោះគឺជាម៉ាស៊ីនចាក់សាំង ឬក៏ម៉ាស៊ីនចាក់ម៉ាស៊ូត ដែលនៅខាងលើគឺម៉ាស៊ីន ចំណែកឯនៅក្នុងទឹកគឺជាកង្ហារ ដែលយើងហៅថាស្លាបចាក់ អញ្ចឹងស្លាបចាក់គឺនៅក្នុងទឹកកំពុងតែបក់ទឹកដើម្បីឲ្យរុញទូកឲ្យទៅមុខ អញ្ចឹងនៅពេលដែលស្លាបចាក់វិលកាន់តែញាប់ ទូកកាន់តែទៅលឿន ប្រសិនបើយើងចង់បង្អង់ល្បឿន យើងត្រូវបន្ថយស្លាបចាក់កុំឲ្យវាវិលញាប់ពេក អញ្ចឹងទូកនេះគឺជាទូកម៉ាស៊ីន។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ គឺជាប្រភេទកប៉ាល់ យើងហៅថាកប៉ាល់ អញ្ចឹងនៅពេលដែល ទូកនៅពេលដែលតូច យើងហៅថាទូក នៅពេលដែលវាលឿន យើងហៅថាកាណូត ប៉ុន្តែនៅពេលដែលទូកនោះធំ យើងហៅថាកប៉ាល់ អញ្ចឹងនៅក្នុងរូបភាពនេះ គឺមានកប៉ាល់ចំនួនមួយ ដែលជាកប៉ាល់ដឹកទំនិញ ដែលយើងឃើញនៅលើកប៉ាល់នោះ គឺមានយុថ្កាមួយសម្រាប់បោះឲ្យជាប់ទៅនឹងទឹក អញ្ចឹងកប៉ាល់គឺ នៅពេលដែលចតនៅកំពង់ផែ គឺយើងអត់ប្រើប្រាស់ខ្សែពួរ ដើម្បីទាក់ទៅនឹងកំពង់ផែនោះទេ ដោយសារតែកប៉ាល់គឺធំ ដូច្នេះប្រើខ្សែពួរអត់ជាប់ទេ វាអាចនឹងដាច់ខ្សែពួរ អញ្ចឹងដើម្បីចតកប៉ាល់ គេត្រូវប្រើយុថ្កា ដែលយុថ្កាគឺជាច្រវាក់ដែក ដែលចងភ្ជាប់នឹងដែកមួយដុំយ៉ាងធំនិងធ្ងន់ ដែលអាចទប់លំនឹងកប៉ាល់បាន អញ្ចឹងដែក ដុំដែកដែលធំនោះ គឺគេចងភ្ជាប់ទៅនឹងច្រវាក់ចេញពីទូក អញ្ចឹងនៅពេលដែលគេចង់ឈប់ គឺគេត្រូវទម្លាក់ដុំដែកនោះ ចូលទៅក្នុងរហូតដល់ទៅដល់បាតទឹក ឬក៏បាតទន្លេ ឬក៏បាតសមុទ្រ ដើម្បីឲ្យទូកនោះមានលំនឹង អញ្ចឹងជាទូទៅកប៉ាល់ គឺយើងប្រើប្រាស់តែនៅលើផ្ទៃសមុទ្រតែប៉ុណ្ណោះ ព្រោះកប៉ាល់គឺធំ ដូច្នេះសមុទ្រគឺធំដែរ អញ្ចឹងកប៉ាល់ងាយស្រួលក្នុងការបើកបរ ប្រសិនបើយើងប្រើប្រាស់កប៉ាល់នៅលើផ្ទៃទន្លេគឺវារាក់ ហើយវាតូច អញ្ចឹងកប៉ាល់អាចនឹងកឿង អាចមិនទៅមុខ អញ្ចឹងកប៉ាល់អត់ទៅមុខទេ នៅពេលដែលបើកនៅទន្លេ ដូច្នេះគេត្រូវបើកនៅសមុទ្រ ដែលកប៉ាល់ជាទូទៅគឺដឹកកុងតឺន័រ បានន័យថាដឹកទូកុងតឺន័រ ដើម្បីដឹកជញ្ជូនទំនិញ ពីប្រទេសមួយទៅប្រទេសមួយ ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ អាចជាកប៉ាល់ចេញពីប្រទេសចិនទៅដល់ប្រទេសអាមេរិក ឬក៏ចេញពីប្រទេសកម្ពុជាទៅរកប្រទេសថៃជាដើម ដែលនៅលើនោះគឺមានទំនិញជាច្រើន ដែលនៅក្នុងកុងតឺន័រ អញ្ចឹងការដឹកជញ្ជូនអីវ៉ាន់ ឬក៏ដឹកជញ្ជូនទំនិញតាមផ្លូវទឹក វាអាចមានការយឺតយ៉ាវជាងការដឹកជញ្ជូនអីវ៉ាន់ ឬក៏ទំនិញតាមផ្លូវអាកាស និងតាមផ្លូវគោក ព្រោះផ្លូវទឹកគឺមាន គឺយើងបើកបរបានយឺតៗ ហើយផ្ទៃទឹកធំ គឺមានរលក ដូច្នេះគឺមានឧបសគ្គច្រើន ក្នុងការដឹកទំនិញតាមផ្ទៃទឹក ប៉ុន្តែប្រសិនបើយើងដឹកទំនិញតាមផ្លូវអាកាស គឺងាយស្រួល គឺវាលឿន អញ្ចឹងយើងអាចដឹកបានឆាប់រហ័ស ដូច្នេះនៅក្នុងរូបភាពនេះ គឺជាការដឹកជញ្ជូនទំនិញតាមផ្ទៃទឹក ប្រហែលជាការដឹកទំនិញពីប្រទេសចិនទៅប្រទេសវៀតណាមជាដើម ដែលទំនិញទាំងអស់នោះ គេដាក់នៅក្នុងកុងតឺន័រ ហើយគេដាក់នៅលើកប៉ាល់ដើម្បីដឹកជញ្ជូន។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.